## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែសីហា ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ៦០ សសរ.

### ស្តីពីការបង្កើតគណៈកម្មការធ្វើជំរឿនមន្ត្រីរាជការ និង វិភាគមុខងារ

***

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

### សំរេច

**ប្រការ ១ ៖** បង្កើតគណៈកម្មការមួយ ដើម្បីធ្វើជំរឿនមន្ត្រីរាជការស៊ីវិល និងវិភាគមុខងារ ក្រសួង និងរដ្ឋលេខាធិការដ្ឋានរបស់រាជរដ្ឋាភិបាល នៅទូទាំងប្រទេស ។

**ប្រការ ២ ៖** គណៈកម្មការនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដែលមានសមាសភាព ដូចតទៅ ៖

១- ឯកឧត្តម ស៊ុំ ម៉ានិត អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ប្រធាន

២- ឯកឧត្តម តេវ្រ ម៉ុនមិន អគ្គលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អនុប្រធាន

៣- ឯកឧត្តម ង៉ើន សុខសំក្តិ អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤- លោក ចៅ សេដ្ឋាណា អគ្គនា. រង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

៥- លោក ឈឹម ឡុន អគ្គនាយករងក្រសួងអប់រំ សមាជិក

៦- លោក ខៀវ ចំនួមិនឡឿន ប្រធាននាយកដ្ឋានក្របខ័ណ្ឌរដ្ឋ-មុខងារសាធារ. សមាជិក

៧- លោក ង៉ី ទិចិត្រ ប្រធាននាយកដ្ឋានបុគ្គលិកក្រសួងសុខាភិបាល សមាជិក

៨- លោក ឌុច សុន ប្រធាននាយកដ្ឋានបុគ្គលិកក្រសួងមហាផ្ទៃ សមាជិក

៩- លោក ឡាយ ឈាន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សមាជិក

១០- លោក ឆេង សាំឆាន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សមាជិក

១១- លោក នីខ សុខៃ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សមាជិក

១២- លោក ឈួន ឆាម អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សមាជិក

១៣- លោក សំ ម៉ុនណា ប្រធានការិយាល័យរដ្ឋបាល-បុ.ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៤- លោក ម៉ោក សុផារិន ប្រធាននាយកដ្ឋានបុគ្គលិកក្រសួងសេដ្ឋកិច្ច សមាជិក

ប្រការ ៣ : គណៈកម្មការនេះ ដំណើរការ ការងារក្រោមការដឹកនាំរបស់ប្រធាន ។

ប្រការ ៤ : គណកម្មការធ្វើជំរឿនមន្ត្រីរាជការ និងវិភាគមុខងារនេះ មានភារកិច្ចសំខាន់ដូចខាងក្រោម ៖

- ដឹកនាំ តាមរបស់រួម និងអនុម័តរាល់កិច្ចការទូទៅ ដែលពាក់ព័ន្ធក្នុងការធ្វើជំរឿនមន្ត្រីរាជការ និងវិភាគមុខងារ
- រៀបចំ និងបង្កើតក្រុមប្រតិបត្តិការផ្សេងៗតាមការចាំបាច់ សំរាប់ដំណើរការជំរឿនមន្ត្រីរាជការ និងវិភាគមុខងារ
- ធ្វើរបាយការណ៍ ស្តីពីការប្រព្រឹត្តិទៅ និងលទ្ធផលនៃការងារជំរឿនមន្ត្រីរាជការ និងវិភាគមុខងារជូនក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ពិនិត្យ និងដាក់ជូនរាជរដ្ឋាភិបាល ។

ប្រការ ៥ : គណៈកម្មការធ្វើជំរឿនមន្ត្រីរាជការ និងវិភាគមុខងារ និងរៀបចំចេញសេចក្តីណែនាំលំអិតមួយ សំរាប់ឲ្យក្រសួង និងរដ្ឋលេខាធិការដ្ឋានទាំងអស់អនុវត្តដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ដើម្បីសំរេចទិសដៅរបស់រាជរដ្ឋាភិបាល ។

ប្រការ ៦ : ក្រសួង និងរដ្ឋលេខាធិការដ្ឋានទាំងអស់ ត្រូវទទួលបន្ទុករៀងៗខ្លួន និងចូលរួមសហការឲ្យបានសកម្ម និងមានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ ៧ : គណៈកម្មការធ្វើជំរឿនមន្ត្រីរាជការ និងវិភាគមុខងារ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត-ក្រុង ប្រធានក្រុមប្រឹក្សាកំណែ

ទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

ជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ក្រុមប្រឹក្សាក្រុមការទីស្តីការគណៈរដ្ឋមន្ត្រី

ប្រធាន

សុខ អាន

***

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៦១ សសរ.

## ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅក្រៅប្រទេស ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។